ដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី
New Generation Pedagogical Research Department

# វិធីសាស្ត្របង្រៀន

## ការសិក្សាអាស្រ័យលើបញ្ហា

Problem-Based Learning



អោក ណោត

២០២៦

# វិធីសាស្រ្តបង្រៀន
# ការសិក្សាអាស្រ័យលើបញ្ហា
# Problem-Based Learning

អោក ណោត

២០២៦

# បំលែងបញ្ហាទៅជាបញ្ញា បណ្ដុះសិស្ស
# ជាអ្នកដោះស្រាយជាក់ស្តែង។



# មាតិកា

អ្វីជាការសិក្សាផ្អែកលើបញ្ហា ( Problem-based learning ) ..................................................1

ហេតុអ្វីត្រូវប្រើប្រាស់ការសិក្សាផ្អែកលើបញ្ហា ?..................................................1

លក្ខណៈសំខាន់ៗនៃការសិក្សាអាស្រ័យលើបញ្ហា (Key Characteristics)..................................................2

តួនាទីរបស់គ្រូបង្រៀន និងសិស្ស (Roles)..................................................2

ឧទាហរណ៍ជាក់ស្តែងនៃការអនុវត្ត PBL៖..................................................3

បញ្ហាប្រឈមនៃវិធីសាស្ត្រ PBL (Limitations) ..................................................6

ដំណោះស្រាយដើម្បីអនុវត្ត PBL ឱ្យមានប្រសិទ្ធភាព (Solutions)..................................................6

គំរូកិច្ចតែងការបង្រៀនការសិក្សាអាស្រ័យលើបញ្ហា (PBL Lesson Plan)..................................................8

ក្បួន និងរូបមន្តបង្កើតសេណារីយ៉ូបញ្ហា (GRASPS Framework)..................................................21

ទម្រង់គំរូបង្កើតសេណារីយ៉ូ (Scenario Design Template)..................................................22

ឧទាហរណ៍នៃការអនុវត្តរូបមន្ត GRASPS ជាក់ស្តែង ..................................................23

ការប្រើប្រាស់បញ្ញាសិប្បនិម្មិត (Generative AI) ដើម្បីរចនាសេណារីយ៉ូបញ្ហា GRASPS..................................................24

គំរូនិទ្ទេសបទវាយតម្លៃការងារក្រុម (Group Work Rubric) ..................................................26

គំរូនិទ្ទេសបទវាយតម្លៃបទបង្ហាញ និងដំណោះស្រាយ (Presentation & Solution Rubric)..................................................27

ទម្រង់វាយតម្លៃមិត្តភក្តិ (Peer Assessment Form)..................................................29

ឯកសារយោង (Reference) ..................................................32

# **អារម្ភកថា**

នៅក្នុងយុគសម័យសតវត្សទី២១ដែលបរិបទសង្គម និងបច្ចេកវិទ្យាមានការវិវឌ្ឍយ៉ាងឆាប់រហ័ស ការអប់រំមិនអាចនៅត្រឹមតែការផ្ទេរចំណេះដឹងពីគ្រូទៅសិស្សនោះទេ។ អ្វីដែលសិស្សានុសិស្សត្រូវការបំផុតនៅពេលនេះ គឺបំណិនក្នុងការត្រិះរិះពិចារណា និងសមត្ថភាពក្នុងការវិភាគដោះស្រាយបញ្ហាជាក់ស្តែង។ ផ្អែកលើភាពចាំបាច់នេះ សៀវភៅ **«ការសិក្សាអាស្រ័យលើបញ្ហា (Problem-Based Learning)** ត្រូវបានចងក្រងឡើងដើម្បីជាត្រីវិស័យ និងជាជំនួយស្មារតីដល់អ្នកអប់រំទាំងអស់។ ការសិក្សាអាស្រ័យលើបញ្ហា(PBL) គឺជាវិធីសាស្ត្របង្រៀនដ៏មានសក្តានុពលដែលផ្លាស់ប្តូរតួនាទីសិស្សពីអ្នកទទួលព័ត៌មានអសកម្មទៅជាអ្នកស្រាវជ្រាវ និងជាអ្នកដោះស្រាយបញ្ហាយ៉ាងសកម្ម។ តាមរយៈសៀវភៅនេះ លោកអ្នកនឹងបានស្វែងយល់ស៊ីជម្រៅតាំងពីទ្រឹស្តីមូលដ្ឋានរហូតដល់ការអនុវត្តជាក់ស្តែងនៅក្នុងថ្នាក់រៀនដូចជាការបង្កើតសេណារីយ៉ូបញ្ហា **(Scenario)** ដែលទាក់ទាញ និងឆ្លុះបញ្ចាំងពីបញ្ហាក្នុងសង្គម។

ជាឧទាហរណ៍ដូចដែលបានបង្ហាញក្នុងគំរូមេរៀននៃសៀវភៅនេះស្រាប់ ការឱ្យសម្តែងសិស្សជាតួអង្គ «មន្ត្រីបរិស្ថានវ័យក្មេង» ដើម្បីវិភាគរកទំនាក់ទំនងរវាងកំណើនប្រជាជន និងកង្វក់អាកាសគឺជាការជំរុញឱ្យពួកគេចេះភ្ជាប់ទ្រឹស្តីក្នុងសៀវភៅទៅនឹងស្ថានភាពសង្គមពិត។ សៀវភៅនេះក៏បានបង្ហាញផងដែរពីការរួមបញ្ចូលវិធីសាស្ត្រ **PBL** ជាមួយនឹង បច្ចេកទេសបង្រៀនគាំទ្រផ្សេងៗទៀត ដូចជាការគិតជាបុគ្គល ជាដៃគូ និងចែករំលែក **(Think Pair Share)** រួមទាំងការប្រើប្រាស់បច្ចេកវិទ្យាក្នុងថ្នាក់រៀន(ដូចជាកម្មវិធី **Flippity**) ដើម្បីធ្វើឱ្យដំណើរការនៃការសហការស្វែងរកដំណោះស្រាយកាន់តែមានភាពរស់រវើក។

ការលេចចេញជារូបរាងនៃស្នាដៃនេះ គឺកើតចេញពីការខិតខំប្រឹងប្រែងស្រាវជ្រាវ និងបទពិសោធន៍ផ្ទាល់ក្នុងការបង្រៀន។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារ**នៃដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី** ដែលតែងតែផ្តល់ការគាំទ្រ និងលើកទឹកចិត្តក្នុងដំណើរការសរសេរកូនសៀវភៅនេះ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សៀវភៅមួយក្បាលនេះនឹងក្លាយជាមគ្គុទ្ទេសក៍ដ៏សំខាន់សម្រាប់លោកគ្រូ អ្នកគ្រូក្នុងការរៀបចំសកម្មភាពបង្រៀនដែលពោរពេញដោយថាមពល និងចូលរួមបណ្តុះបណ្តាលយុវជនជំនាន់ក្រោយឱ្យក្លាយជាអ្នកដោះស្រាយបញ្ហាដ៏ពូកែសម្រាប់សង្គមជាតិ។

**ភ្នំពេញ, ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៦**
**អោក ណេត**
**គ្រូឧទ្ទេសវិធីសាស្ត្របង្រៀន (NGPRD, NIE)**

## **គណៈកម្មការត្រួតពិនិត្យខ្លឹមសារ**

| | |
|---|---|
| ១. **Stanisla Kolwalski** | អ្នកអភិវឌ្ឍកម្មវិធីសិក្សា និងជាទីប្រឹក្សានៃ NGPRD |
| ២. លោកគ្រូ **គា សុបញ្ញា** | គ្រូបង្រៀនភាសាអង់គ្លេស-ខ្មែរ និងជាអតីតគរុនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេសប្រឹក្សាគរុកោសល្យជំនាន់ទី៤ |

## **គណៈកម្មការត្រួតពិនិត្យអក្ខរាវិរុទ្ធ**

| | |
|---|---|
| ១. លោកគ្រូ **ឡឿន ទិចិត្រ** | គ្រូបង្រៀនឯកទេសសីលធម៌ពលរដ្ឋ និងជាគរុនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេសប្រឹក្សាគរុកោសល្យ |
| ២. លោកគ្រូ **ម៉ាច សុគន្ធ** | គ្រូបង្រៀនឯកទេសភាសាអង់គ្លេស និងជាគរុនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេសប្រឹក្សាគរុកោសល្យ |
| ៣. អ្នកគ្រូ **កុយ ចាន់ណា** | គ្រូបង្រៀនឯកទេសជីវវិទ្យា និងជាគរុនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេសប្រឹក្សាគរុកោសល្យ |
| ៤. អ្នកគ្រូ **សំអាត ម៉ូនីកាដារីយ៉ា** | គ្រូបង្រៀនឯកទេសផែនដី បរិស្ថាន និងជាគរុនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេសប្រឹក្សាគរុកោសល្យ |

សៀវភៅស្តីពីការសិក្សាអាស្រ័យលើបញ្ហានេះ ត្រូវបានចែករំលែកក្រោមអាជ្ញាប័ណ្ណគ្រីអេធីវ ខំមិនស៍ (Creative Commons) សម្រាប់កំណែអេឡិចត្រូនិចជាភាសាខ្មែរ។

**CC BY-NC-ND 4.0**

**Attribution-NonCommercial-NoDerivatives 4.0 International**

អាជ្ញាបណ្ណនេះអនុញ្ញាតឱ្យអ្នកប្រើប្រាស់បន្តចម្លង និងចែកចាយឯកសារគ្រប់ទម្រង់ ឬមធ្យោបាយណាមួយ *ក្នុងទម្រង់ដែលគ្មានការកែប្រែតែប៉ុណ្ណោះ*សម្រាប់ *គោលបំណងមិនមែនពាណិជ្ជកម្ម* និង *លុះត្រាតែមានការផ្តល់ក្រេឌីត ដល់ស្ថាបនិក*។

**តាមរយៈ CC BY-NC-ND** រួមបញ្ចូលធាតុដូចខាងក្រោម៖

**BY (ការផ្តល់ក្រេឌីត)៖** ក្រេឌីតត្រូវផ្តល់ដល់ស្ថាបនិក ពោលគឺអ្នកនិពន្ធដែលបានចុះបញ្ជីជាមួយអត្ថបទនីមួយៗ និងជាមួយ **ដេប៉ាត់ម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRD)** ។

**NC (មិនមែនពាណិជ្ជកម្ម)៖** អនុញ្ញាតឱ្យប្រើប្រាស់ស្នាដៃនេះសម្រាប់តែ *គោលបំណងមិនមែនពាណិជ្ជកម្ម*ប៉ុណ្ណោះ។

**ND (មិនមានការកែប្រែ ឬសម្រួលលើស្នាដៃដើម)៖** *មិនអនុញ្ញាត* ឱ្យមានការបង្កើតស្នាដៃកែច្នៃ ឬសម្របសម្រួលលើខ្លឹមសារណាមួយនៃស្នាដៃដើមឡើយ។

**ដើម្បីសុំសិទ្ធិក្នុងការបកប្រែ សូមទាក់ទងមកលោកគ្រូ អេន ណេត និងដេប៉ាត់ម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRD)។**

**អ៊ីមែល៖** netjb0304@gmail.com

**តំណ៖** https://www.kapekh.org/en/what-we-do/16/?pro_id=40

## អ្វីជាការសិក្សាអាស្រ័យលើបញ្ហា ( Problem-Based Learning)

ការសិក្សាអាស្រ័យលើបញ្ហា (Problem-Based Learning-PBL) គឺជាវិធីសាស្រ្តបង្រៀនដែលផ្តោតលើសិស្សជាចម្បង។ យោងតាមលោក Barrows (1996) ដែលជាបិតាស្ថាបនិកមួយរូបនៃវិធីសាស្រ្តនេះ PBL តម្រូវឱ្យសិស្សរៀនអំពីមុខវិជ្ជាមួយតាមរយៈការធ្វើការងារជាក្រុមដើម្បីដោះស្រាយបញ្ហាជាក់ស្តែងនៅក្នុងជីវិតពិតដែលមិនមានចម្លើយកំណត់ទុកជាមុន។ ស្របគ្នានេះដែរ Savery (2006) បានគូសបញ្ជាក់ថាបញ្ហាដ៏ស្មុគស្មាញទាំងនេះហើយ គឺជាកម្លាំងចលករចម្បងដែលជំរុញទឹកចិត្តនិងបណ្តុះទម្លាប់នៃការរៀនសូត្រដោយការដឹកនាំខ្លួនឯង (Self-directed learning) របស់សិស្ស។

PBL ខុសពីការបង្ហាញបញ្ហាហើយធ្វើការឧទ្ទេស តែវាជាចំណុចចាប់ផ្តើមនៃការស្វែងរកចំណេះដឹងថ្មី។ នៅក្នុងវិធីសាស្រ្តប្រពៃណី គ្រូអាចនឹងពន្យល់ទ្រឹស្តីជាមុនរួចទើបដាក់បញ្ហាឱ្យសិស្សអនុវត្តជាលំហាត់តាមក្រោយ ប៉ុន្តែសម្រាប់ PBL វិញបញ្ហាត្រូវបានដាក់ឱ្យសិស្សមុនពេលពួកគេទទួលបានព័ត៌មាន ឬចំណេះដឹងមូលដ្ឋាន។ ស្ថានភាពនេះតម្រូវឱ្យសិស្សធ្វើការស៊ើបអង្កេតស្រាវជ្រាវនិងរៀនសូត្រនូវអ្វីដែលចាំបាច់ដោយខ្លួនឯងដើម្បីឈានទៅរកដំណោះស្រាយ។ ក្នុងបរិបទនេះគ្រូបង្រៀនលែងជាអ្នកផ្ទេរចំណេះដឹង (Knowledge Transmitter) ទៀតហើយ តែបានផ្លាស់ប្តូរតួនាទីទៅជាអ្នកសម្របសម្រួល (Facilitator) ដែលចាំជួយតម្រង់ទិស សួរជាសំណួរត្រិះរិះនិងលើកទឹកចិត្តសិស្សពេញមួយដំណើរការសិក្សា។

ទោះជាយ៉ាងណាក៏ដោយ នេះមិនមែនមានន័យថា គ្រូបង្រៀនត្រូវតែងាកមកអនុវត្តតែវិធីសាស្រ្តមួយនេះ ហើយបោះបង់ចោលនូវវិធីសាស្រ្តផ្សេងទៀត ដែលធ្លាប់ទទួលបានជោគជ័យកន្លងមកនោះទេ។ ផ្ទុយទៅវិញ គ្រូបង្រៀនគួរមានភាពបត់បែន និងច្នៃប្រឌិតក្នុងការជ្រើសរើសវិធីសាស្រ្តបច្ចេកទេស និងការប្រើប្រាស់ធនធានដែលមានស្រាប់ដើម្បីធានាឱ្យដំណើរការបង្រៀននិងរៀនប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ហេតុអ្វីត្រូវប្រើប្រាស់ការសិក្សាអាស្រ័យលើបញ្ហា?

លោក Nilson (2010) បានរាយបញ្ជីលទ្ធផលនៃការសិក្សាដូចខាងក្រោមដែលទាក់ទងនឹង PBL ហើយគម្រោង PBL ដែលបានរៀបចំយ៉ាងល្អ ផ្តល់ឱកាសដល់សិស្សក្នុងការអភិវឌ្ឍជំនាញទាក់ទងនឹង៖

- ការធ្វើការងារជាក្រុម និងការគ្រប់គ្រងគម្រោង និងការកាន់តួនាទីជាអ្នកដឹកនាំ
- ការទំនាក់ទំនងផ្ទាល់មាត់ និងការសរសេរនិងការយល់ដឹងពីខ្លួនឯង និងការវាយតម្លៃលើដំណើរការក្រុម
- ការធ្វើការងារដោយឯករាជ្យ និងការគិតបែបស៊ីជម្រៅ និងការវិភាគ
- ការពន្យល់អំពីគោលគំនិតស៊ីជម្រៅ និងការរៀនសូត្រដោយការដឹកនាំខ្លួនឯង

- ការអនុវត្តខ្លឹមសារមេរៀនទៅព្រមទាំងឧទាហរណ៍ក្នុងពិភពជាក់ស្តែង និងការស្រាវជ្រាវ និងអន្តរកម្មព័ត៌មាន(សមត្ថភាពក្នុងការស្វែងយល់ព័ត៌មាន)ព្រមទាំងការដោះស្រាយបញ្ហាអន្តរមុខវិជ្ជាផ្សេងៗគ្នា។

ការអនុវត្ត PBL មិនត្រឹមតែជួយឱ្យសិស្សយល់ដឹងពីខ្លឹមសារមេរៀនប៉ុណ្ណោះទេ តែថែមទាំងជួយអភិវឌ្ឍការគិតកម្រិតខ្ពស់របស់សិស្សផងដែរ។ យោងតាមការស្រាវជ្រាវរបស់ Hmelo Silver (2004) វិធីសាស្ត្រ PBL បានជួយយ៉ាងសកម្មក្នុងការអភិវឌ្ឍសមត្ថភាពត្រិះរិះពិចារណា (Critical thinking) និងជំនាញដោះស្រាយបញ្ហាប្រកបដោយភាពបត់បែន ដែលអាចឱ្យសិស្សផ្ទេរចំណេះដឹងទាំងនោះទៅកាន់ស្ថានភាពថ្មីៗបាន។

លក្ខណៈពិសេសមួយនៃ PBL គឺការធ្វើការងារជាក្រុមនិងការពិភាក្សា។ ផ្អែកលើទ្រឹស្តីស្ថាបនានិយមសង្គម (Social Constructivism) របស់លោក Vygotsky (1978) ការរៀនសូត្ររបស់មនុស្សទទួលបានលទ្ធផលល្អបំផុតនិងមានការអភិវឌ្ឍកម្រិតខ្ពស់នៅពេលដែលអ្នកសិក្សាមានអន្តរកម្មសង្គម និងសហការគ្នាដើម្បីស្វែងរកប្រភពនៃបញ្ហាណាមួយ។ ទន្ទឹមនឹងនេះ Bonwell និង Eison (1991) ក៏បានសង្កត់ធ្ងន់ដែរថាក្នុងការសិក្សាបែបសកម្ម (Active Learning) សិស្សមិនត្រឹមតែស្តាប់នោះទេ តែពួកគេត្រូវតែចូលរួមអានសរសេរពិភាក្សា ដោះស្រាយបញ្ហា និងប្រើប្រាស់ការគិតកម្រិតខ្ពស់ (ការវិភាគ ការសំយោគ និងការបង្កើតថ្មី)។

## លក្ខណៈសំខាន់ៗនៃការសិក្សាអាស្រ័យលើបញ្ហា (Key Characteristics)

- **បញ្ហាជាក់ស្តែង និងទូទៅ (Authentic Open Ended Problems)៖** សិស្សដោះស្រាយសេណារីយ៉ូជាក់ស្តែងឬស្រដៀងនឹងការពិតដែលមានដំណោះស្រាយច្រើនមិនមែនជាចម្លើយដែលបានកំណត់ទុកជាមុន។
- **ការស្រាវជ្រាវដឹកនាំដោយសិស្ស (Student Driven Inquiry)៖** អ្នកសិក្សាកំណត់នូវអ្វីដែលពួកគេចាំបាច់ត្រូវដឹងធ្វើការស្រាវជ្រាវវិភាគព័ត៌មាន និងបង្កើតការយល់ដឹងដោយឯករាជ្យ។
- **គ្រូបង្រៀនជាអ្នកសម្របសម្រួល (Teacher as Facilitator)៖** គ្រូបង្រៀនណែនាំការគិតជាជាងការបញ្ជូនខ្លឹមសារមេរៀនដោយសួរសំណួរជំរុញជួយគាំទ្រការស្រាវជ្រាវនិងជួយដល់ការឆ្លុះបញ្ចាំង។
- **ការសហការ និងការឆ្លុះបញ្ចាំង (Collaboration & Reflection)៖** សិស្សធ្វើការជាក្រុមចែករំលែកគំនិត ជជែករកដំណោះស្រាយនិងឆ្លុះបញ្ចាំងទាំងលើលទ្ធផលនិងដំណើរការនៃការសិក្សា។

## តួនាទីរបស់គ្រូបង្រៀន និងសិស្ស (Roles)

- **តួនាទីរបស់គ្រូបង្រៀន (The Role of the Teacher)៖** គ្រូបង្រៀនដើរតួជាគ្រូបង្វឹកការសិក្សាមិនមែនជាអ្នកបញ្ជូនខ្លឹមសារមេរៀនទេ គឺណែនាំការស្រាវជ្រាវសួរសំណួរត្រិះរិះដែលជួយគាំទ្រការគិត និងជំរុញភាពរីកចម្រើននៃការយល់ដឹង។

- **តួនាទីរបស់សិស្ស (The Role of the Students)៖** សិស្សគឺជាអ្នកស៊ើបអង្កេតសកម្មដែលទទួលខុសត្រូវក្នុងការកំណត់តម្រូវការសិក្សាស្វែងរកប្រភពព័ត៌មានវិភាគទិន្នន័យ និងសំយោគចំណេះដឹង។

**ឧទាហរណ៍ជាក់ស្តែងនៃការអនុវត្ត PBL៖**

## ១. មុខវិជ្ជាផែនដី និងបរិស្ថាន៖ យុទ្ធនាការសង្គ្រោះប្រភពទឹក

នៅក្នុងមុខវិជ្ជាផែនដី និងបរិស្ថានសិស្សានុសិស្សនឹងត្រូវបានដាក់ឱ្យដោះស្រាយបញ្ហាជាក់ស្តែងជុំវិញការធ្លាក់ចុះគុណភាពទឹកយ៉ាងខ្លាំងនៅតាមបឹងឬទន្លេក្នុងសហគមន៍ដែលបណ្តាលឱ្យត្រីងាប់ និងប៉ះពាល់ដល់សុខភាពអ្នកភូមិ។ សិស្សត្រូវបែងចែកជាក្រុមនិងទទួលតួនាទីជា "អ្នកស្រាវជ្រាវបរិស្ថាន" ដោយត្រូវចុះសិក្សាពីប្រព័ន្ធអេកូឡូស៊ីទឹកនិងស្រាវជ្រាវរកមូលហេតុពិតប្រាកដនៃការបំពុលដូចជាកាកសំណល់ពីរោងចក្រការចោលសំរាមឬការប្រើប្រាស់ជីគីមីជាដើម។ ជាដំណោះស្រាយក្រុមនីមួយៗត្រូវចងក្រងគម្រោងស្នើសុំ **(Proposal)** ដែលបង្ហាញពីយុទ្ធសាស្ត្រសម្អាត និងទប់ស្កាត់ប្រកបដោយចីរភាពរួចយកទៅធ្វើបទបង្ហាញសាកល្បងការពារគម្រោងរបស់ខ្លួននៅចំពោះមុខគ្រូបង្រៀន ឬមិត្តរួមថ្នាក់ដែលដើរតួជា "អាជ្ញាធរមូលដ្ឋាន"។

## ២. មុខវិជ្ជាប្រវត្តិវិទ្យា៖ ការរស់ឡើងវិញនៃអត្តសញ្ញាណវប្បធម៌

សម្រាប់មុខវិជ្ជាប្រវត្តិវិទ្យាការរៀនសូត្រត្រូវបានផ្សារភ្ជាប់ទៅនឹងការអភិរក្សដោយលើកយកបញ្ហានៃការបំភ្លេចចោលតំបន់ប្រវត្តិសាស្ត្រឬវត្តអារាមចាស់ៗនៅក្នុងមូលដ្ឋានដែលអាចធ្វើឱ្យយុវជនជំនាន់ក្រោយប្រឈមនឹងការបាត់បង់អត្តសញ្ញាណ។ ក្នុងតួនាទីជា"អ្នកជំនាញផ្នែកទេសចរណ៍និងវប្បធម៌"សិស្សត្រូវចុះផ្ទាល់ដើម្បីសម្ភាសន៍ចាស់ព្រឹទ្ធាចារ្យស្វែងរកឯកសារប្រវត្តិសាស្ត្រសិក្សាពីចំណុចទាក់ទាញនិងរៀនពីជំនាញចងក្រងសាច់រឿង **(Storytelling)**។ លទ្ធផលរំពឹងទុកប្រកបដោយភាពច្នៃប្រឌិតដែលសិស្សត្រូវបង្កើតចេញគឺសៀវភៅមគ្គុទ្ទេសក៍ទេសចរណ៍ **(Travel Brochure)** វីដេអូខ្លីសម្រាប់ផ្សព្វផ្សាយលើបណ្តាញសង្គមឬផែនទីទេសចរណ៍សហគមន៍ដើម្បីចូលរួមចំណែកទាក់ទាញភ្ញៀវទេសចរនិងអភិរក្សតំបន់ទាំងនោះឱ្យបានគង់វង្ស។

## ៣. មុខវិជ្ជាភាសាបរទេស៖ ការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ

នៅក្នុងថ្នាក់ភាសាបរទេសបញ្ហាព័ត៌មានមិនពិត **(Fake News)** នៅលើបណ្តាញសង្គមដែលបង្កការភ័យខ្លាចដល់សន្តិសុខ និងសុខុមាលភាពសង្គម ត្រូវបានលើកយកមកធ្វើជាប្រធានបទពិភាក្សា។ សិស្សត្រូវបែងចែកជាក្រុមដោយដើរតួជា"ក្រុមនិពន្ធនាយក និងអ្នកត្រួតពិនិត្យការពិត"**(Fact-Checkers)** ដើម្បីវិភាគស៊ីជម្រៅលើភាពខុសគ្នារវាងមតិបុគ្គល និងការពិត ព្រមទាំងសិក្សាពីការប្រើប្រាស់ភាសាប្រកបដោយឥទ្ធិពលនិងសុចរិតភាព។ ជាដំណោះស្រាយ សិស្សត្រូវរួមគ្នាបង្កើតព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍ឬបង្កើតយុទ្ធនាការ "យល់ដឹងពីព័ត៌មាន"នៅក្នុងសាលាដោយលើកយកព័ត៌មានក្លែងក្លាយដែលកំពុងល្បីមកបកស្រាយការពិត និងចែករំលែកវិធីសាស្ត្រផ្ទៀងផ្ទាត់ព័ត៌មានទៅកាន់មិត្តភក្តិដទៃទៀត។

### ៤. មុខវិជ្ជារូបវិទ្យាៈ វិស្វកម្មសុវត្ថិភាពចរាចរណ៍ផ្លូវថ្នល់

មុខវិជ្ជារូបវិទ្យានឹងក្លាយជាការអនុវត្តជាក់ស្តែងដ៏គួរឱ្យចាប់អារម្មណ៍តាមរយៈការដោះស្រាយបញ្ហាគ្រោះថ្នាក់ចរាចរណ៍ដែលតែងតែកើតមាននៅតំបន់ផ្លូវកោងឬផ្លូវប្រសព្វក្បែរសាលារៀនជាពិសេសនៅរដូវភ្លៀងធ្លាក់ ដែលផ្លូវរអិលនិងបង្កការលំបាកក្នុងការជាន់ហ្វ្រាំង។ សិស្សនឹងទទួលតួនាទីជា"វិស្វករសុវត្ថិភាពចរាចរណ៍" ដោយត្រូវចុះវាស់វែងប្រវែងផ្លូវផ្ទាល់និងប្រើប្រាស់រូបមន្តរូបវិទ្យា( ថាមពលស៊ីនេទិច និងកម្លាំងកកិត ) ដើម្បីគណនារក "ចម្ងាយឈប់នៃយានយន្ត" **(Braking Distance)** ធៀបគ្នារវាងលក្ខខណ្ឌផ្លូវស្ងួត និងផ្លូវសើម។ បន្ទាប់មកក្រុមនីមួយៗត្រូវសរសេររបាយការណ៍បច្ចេកទេសមួយ ដោយប្រើប្រាស់តារាងទិន្នន័យ និងរូបមន្តគណនាត្រឹមត្រូវដើម្បីស្នើសុំកំណត់ល្បឿនសុវត្ថិភាពថ្មី **(Speed Limit)** ឬកំណត់ទីតាំងដាក់ផ្លាកសញ្ញាព្រមានសម្រាប់យកទៅធ្វើបទបង្ហាញជូន នាយកសាលា ឬអាជ្ញាធរពាក់ព័ន្ធ។

## ជំហានក្នុងការអនុវត្តការសិក្សាអាស្រ័យលើបញ្ហា (PBL)

ជំនួសឱ្យការបង្រៀនឯកសារពាក់ព័ន្ធ ហើយបន្ទាប់មកឱ្យសិស្សអនុវត្តចំណេះដឹង ដើម្បីដោះស្រាយបញ្ហាត្រូវតែលើកយកបញ្ហាមកបង្ហាញមុនគេ។ កិច្ចការ PBL អាចមានរយៈពេលខ្លីឬក៏អាចមានភាពស្មុគស្មាញច្រើនជាងនេះដែលចំណាយពេលពេញមួយឆមាស។ ជាញឹកញាប់ PBL គឺផ្តោតលើការងារជាក្រុមដូច្នេះវាមានអត្ថប្រយោជន៍ណាស់ក្នុងការទុកពេលក្នុងថ្នាក់ ដើម្បីរៀបចំសិស្សឱ្យធ្វើការជាក្រុម និងអនុញ្ញាតឱ្យពួកគេចូលរួមក្នុងគម្រោង PBL របស់ពួកគេ។

- **ជាទូទៅ សិស្សត្រូវតែៈ**

**១. បង្ហាញបញ្ហា** (Present the Problem)។

**២. កំណត់នូវអ្វីដែលដឹង និងមិនដឹង** (Identify What’s Known & Unknown)។

**៣. ស្រាវជ្រាវ និងស៊ើបអង្កេត** (Research and Investigate)។

**៤. អភិវឌ្ឍដំណោះស្រាយ** (Develop Solutions)។

**៥. បង្ហាញ និងការពារលទ្ធផល** (Present and Defend Findings)។

**៦. ឆ្លុះបញ្ចាំង និងវាយតម្លៃដំណើរការ** (Reflect and Evaluate the Process)។


1
កំណត់បញ្ហា
2
កំណត់នូវអ្វីដែលដឹង
និងមិនដឹង
3
ស្រាវជ្រាវ និងស៊ើបអង្កេត
4
អភិវឌ្ឍដំណោះស្រាយ
5
បង្ហាញ
និងការពារលទ្ធផល
6
ឆ្លុះបញ្ចាំង
និងវាយតម្លៃដំណើរការ


The 6 Steps of Problem-Based Learning (PBL)
PHASE 1: INVESTIGATION & INQUIRY
Introduce the core challenge or scenario that needs to be solved.
1. Present the Problem
KNOWNS
UNKNOWNS
2. Identify Knowns & Unknowns
Determine what information is already available and what needs to be discovered.
3. Research and Investigate
Conduct active inquiry and gather data to address the knowledge gaps.
PHASE 2: SOLUTION & REFLECTION
4. Develop Solutions
Synthesize research to create actionable answers or prototypes for the problem.
5. Present and Defend Findings
Share results with others and provide evidence-based justifications for the chosen solution.
6. Reflect and Evaluate
Analyze the effectiveness of the solution and the quality of the learning journey.
NotebookLM

ការចាប់ផ្តើមជាមួយការសិក្សាអាស្រ័យលើបញ្ហា ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីលទ្ធផលនៃការសិក្សារបស់គម្រោង។ តើអ្នកចង់ឱ្យសិស្សដឹង ឬអាចធ្វើអ្វីបានខ្លះជាលទ្ធផលនៃការចូលរួមក្នុងកិច្ចការនេះ? កំណត់បញ្ហា និងស្ថានភាពក្នុងពិភពជាក់ស្តែងដែលស្រដៀងទៅនឹងអ្វីដែលសិស្សអាចនឹងជួបប្រទះក្នុងអាជីព ឬជីវិតនៅថ្ងៃអនាគតរបស់ពួកគេ។ ជាញឹកញាប់ករណីសិក្សាគឺជាមូលដ្ឋាននៃសកម្មភាព PBL។
បង្កើតវិធានការជាមូលដ្ឋានពីដំបូងដើម្បីរៀបចំសិស្សធ្វើការប្រកបដោយប្រសិទ្ធភាពនៅក្នុងក្រុម៖

- ណែនាំសិស្សអំពីដំណើរការក្រុម និងធ្វើលំហាត់កម្តៅសាច់ដុំមួយចំនួន ដើម្បីអនុញ្ញាតឱ្យពួកគេអនុវត្តការវាយតម្លៃទាំងការងាររបស់ពួកគេផ្ទាល់និងការងាមិត្តភក្តិរបស់ពួកគេ។
- ពិចារណាឱ្យសិស្សមានឱកាសដើរតួនាទីផ្សេងៗគ្នា ឬបែងចែកការងារក្នុងចំណោមពួកគេផ្ទាល់។ ម្យ៉ាងវិញទៀតគម្រោងនេះ អាចតម្រូវឱ្យសិស្សសន្មតនូវទស្សនៈផ្សេងៗគ្នា ដូចជាទស្សនៈរបស់មន្ត្រីរដ្ឋាភិបាល ម្ចាស់អាជីវកម្មក្នុងស្រុក និងវាយតម្លៃលើកិច្ចការនោះ។

## បញ្ហាប្រឈមនៃវិធីសាស្ត្រ PBL (Limitations)

- **ការចំណាយពេលវេលាច្រើន៖** ការរៀបចំសេណារីយ៉ូបញ្ហានិងការរង់ចាំឱ្យសិស្សស្រាវជ្រាវរកដំណោះស្រាយ ទាមទារពេលវេលាច្រើនជាងការបង្រៀនបែបប្រពៃណី។ ជាក់ស្តែងនៅក្នុងកិច្ចតែងការបង្រៀនដែលមានរយៈពេលត្រឹម៤៥នាទី ដូច្នេះការអនុវត្ត PBL ឱ្យបានពេញលេញនិងស៊ីជម្រៅអាចជួបការ លំបាក និងតឹងតែងផ្នែកពេលវេលា (ចំណាយពេលច្រើន)។
- **ភាពអសកម្មរបស់សិស្សមួយចំនួន** (Free Riding)**៖** ដោយសារ PBL ជាទូទៅផ្តោតលើការធ្វើការងារជាក្រុម វាងាយនឹងមានករណីសិស្សពូកែ ឬសកម្មទទួលរ៉ាប់រងការងារទាំងអស់ ខណៈសិស្សរៀនយឺត ឬអសកម្មមិនបានចូលរួម និងមិនទទួលបានចំណេះដឹងពេញលេញ។
- **ការវង្វេងទិសដៅឬកង្វះចំណេះដឹងមូលដ្ឋាន៖** ប្រសិនបើសិស្សមិនទាន់មានចំណេះដឹងមូលដ្ឋានគ្រប់គ្រាន់លើប្រធានបទនោះទេការទម្លាក់បញ្ហាឱ្យពួកគេដោះស្រាយភ្លាមៗអាចធ្វើឱ្យពួកគេមានអារម្មណ៍តានតឹង បាក់ទឹកចិត្ត និងមិនដឹងថាត្រូវចាប់ផ្តើមពីចំណុចណាជាដើម...។
- **ភាពស្មុគស្មាញក្នុងការវាយតម្លៃ៖** ការដាក់ពិន្ទុ ឬវាយតម្លៃសិស្សនៅក្នុង PBL គឺមានភាពស្មុគស្មាញ ព្រោះគ្រូមិនត្រឹមតែវាយតម្លៃលើលទ្ធផលចុងក្រោយ(ដូចជាការធ្វើបទបង្ហាញ) ប៉ុណ្ណោះទេ តែត្រូវវាយតម្លៃលើដំណើរការនៃការស្រាវជ្រាវ និងការសហការគ្នារបស់សិស្សម្នាក់ៗ។

## ដំណោះស្រាយដើម្បីអនុវត្ត PBL ឱ្យមានប្រសិទ្ធភាព (Solutions)

- **ការគ្រប់គ្រងពេលវេលា និងការបង្រៀនគំរូថ្នាក់រៀនត្រឡប់ (Flipped Classroom)៖** ដើម្បីសន្សំសំចៃម៉ោងក្នុងថ្នាក់ គ្រូអាចចែករំលែកឯកសារឬវីដេអូមូលដ្ឋានឱ្យសិស្សសិក្សានៅផ្ទះជាមុន។ ពេលមក

ដល់ថ្នាក់រៀនពេលវេលាភាគច្រើននឹងត្រូវប្រើសម្រាប់ការពិភាក្សា និងដោះស្រាយបញ្ហាតែម្តង។ លើសពីនេះ ការកំណត់ពេលឱ្យបានច្បាស់លាស់សម្រាប់ជំហាននីមួយៗ គឺជារឿងចាំបាច់បំផុត។

- **ការបែងចែកតួនាទី និងការវាយតម្លៃមិត្តភក្តិ៖** ដើម្បីដោះស្រាយបញ្ហាសិស្សអសកម្ម គ្រូគួរណែនាំសិស្សឱ្យទទួលយកតួនាទីផ្សេងៗគ្នា ឬបែងចែកការងារក្នុងចំណោមពួកគេផ្ទាល់(ឧទាហរណ៍៖ អ្នកដឹកនាំ អ្នកកត់ត្រា អ្នកស្រាវជ្រាវ អ្នកឡើងធ្វើបទបង្ហាញ)។
- **ការប្រើប្រាស់ទម្រង់វាយតម្លៃមិត្តភក្តិ** (Peer Assessment) ក៏ជួយជំរុញឱ្យសិស្សម្នាក់ៗមានទំនួលខុសត្រូវខ្ពស់ជាងមុនផងដែរ។
- **ការប្រើប្រាស់បច្ចេកទេស** Scaffolding**៖** គ្រូមិនត្រូវទុកសិស្សឱ្យដោះស្រាយបញ្ហាដោយឯកោនោះទេ។ គ្រូត្រូវដើរតួជាអ្នកសម្របសម្រួលដោយជួយចោទសួរជាសំណួរបំផុស ដើម្បីតម្រង់ទិសពួកគេនៅពេលពួកគេជួបភាពទាល់ច្រក។ ការណែនាំឱ្យសិស្សកំណត់អ្វីដែលពួកគេដឹងហើយនិងអ្វីដែលត្រូវស្រាវជ្រាវបន្ត គឺជាការជួយតម្រង់ទិសដ៏ល្អ។
- **ការប្រើប្រាស់និទ្ទេសបទវាយតម្លៃ** (Rubrics) **ច្បាស់លាស់៖** គ្រូត្រូវរៀបចំ Rubrics មួយដែលវាយតម្លៃទៅលើផ្នែកសំខាន់ៗដូចជា៖គុណភាពនៃការស្រាវជ្រាវ ជំនាញសហការជាក្រុមការត្រិះរិះពិចារណា និងការធ្វើបទបង្ហាញ។ ការបង្ហាញនិទ្ទេសបទនេះទៅកាន់សិស្សតាំងពីមុនពេលចាប់ផ្តើមគម្រោងនឹងជួយឱ្យពួកគេដឹងពីការរំពឹងទុក និងគោលដៅច្បាស់លាស់។

**គំរូកិច្ចតែងការបង្រៀនការសិក្សាអាស្រ័យលើបញ្ហា (PBL Lesson Plan)**

កិច្ចតែងការបង្រៀន

**មុខវិជ្ជា ៖** ភូមិវិទ្យា

**ជំពូកទី៤ ៖** កង្វក់និងការត្រួតពិនិត្យ

**មេរៀនទី១ ៖** កង្វក់បរិយាកាស

**បង្រៀនថ្នាក់ទី ៖** ថ្នាក់ទី១១

**រយៈពេល ៖** ៤៥នាទី (ម៉ោងទី១)

**វត្ថុបំណងមេរៀន** ក្រោយពីសិក្សាមេរៀននេះចប់សិស្សមានលទ្ធភាព៖

- **វិជ្ជាសម្បទា ៖** ឱ្យនិយមន័យកង្វក់អាកាស បានយ៉ាងច្បាស់លាស់តាមរយៈ សំណួរបំផុស។
- **បំណិនសម្បទា៖** រៀបរាប់បានពីកត្តានិងប្រភពនៃកង្វក់អាកាសបានយ៉ាងច្បាស់លាស់តាមរយៈខ្លឹមសារមេរៀន។
- **បំណិនសម្បទា ៖** វិភាគបានពីទំនាក់ទំនងរវាងកំណើនប្រជាជន និងការកើនឡើងនៃកង្វក់អាកាសតាមរយៈការដោះស្រាយសេណារីយ៉ូបញ្ហាបានយ៉ាងត្រឹមត្រូវ។
- **ចរិយាសម្បទា៖** បណ្តុះស្មារតីសិស្សឱ្យចេះស្រឡាញ់បរិយាកាសល្អនិងរួមចំណែកការពារបរិយាកាសផងដែរ។

**ខ្លឹមសារមេរៀន**

១. កំណើនប្រជាជន

២. ស្ថានភាពបរិយាកាស

៣. ប្រភេទនៃកង្វក់អាកាស

៤. ប្រភពនៃកង្វក់អាកាស

**សម្ភារឧបទ្ទេស**

- **សម្ភារៈគ្រូ ៖** វីដេអូផ្សេងៗទាក់ទងនឹងខ្លឹមសារមេរៀន, LCD projector, Slide, សន្លឹកកិច្ចការ, កម្មវិធី Flippity
- **សម្ភារៈសិស្ស ៖** សៀវភៅកត់ត្រា ប៊ិចខៀវ ក្រហម, សៀវភៅសិស្ស ភូមិវិទ្យាថ្នាក់ទី១១ សន្លឹកកិច្ចការ,

សៀវភៅកិច្ចការផ្ទះ

## វិធីសាស្រ្តបង្រៀន

- **គោលវិធីបង្រៀន៖** ការសិក្សាតាមបែបស្ថាបនានិយម
- **វិធីសាស្រ្តបង្រៀន៖** បែបដោះស្រាយបញ្ហា PBL
- **បច្ចេកទេសបង្រៀន៖** គិត ដៃគូ ចែករំលែក (Think Pair Share)

## ដំណើរកិច្ចតែងការបង្រៀន

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| **ជំហានទី១៖ លំនឹងថ្នាក់ (៣នាទី)** | | |
| - ពិនិត្យអវត្តមាន<br>- អនាម័យ ឯកសណ្ឋាន<br>និងសណ្តាប់ធ្នាប់ក្នុងថ្នាក់រៀន | **រដ្ឋបាលថ្នាក់រៀន** | - សម្អាតថ្នាក់រៀន<br>- ប្រធានថ្នាក់រាយការណ៍អវត្តមាន |
| **ជំហានទី២៖ កែកិច្ចការផ្ទះ និងរំលឹកមេរៀន (៤នាទី)** | | |
| - **កែកិច្ចការផ្ទះ**<br>១.តើតំបន់ណាខ្លះដែលរងនូវការបំពុលខ្លាំងជាងគេ? ព្រោះអ្វី? | **កិច្ចការផ្ទះ**<br>១. តំបន់ដែលរងនូវការបំពុលខ្លាំងជាងគេ គឺ ឆ្នេរសមុទ្រជាយទ្វីបដូចជា ៖<br>សមុទ្រឧត្តរ សមុទ្របាល់ទិច<br>សមុទ្រមេឌីទែរ៉ាណេ។<br>បន្ទាប់គឺឆ្នេរមហាសមុទ្រធំៗ | - សិស្សឡើងឆ្លើយ<br>- សិស្សឡើងឆ្លើយ |

| | | |
|---|---|---|
| - **សួរសំណួររំលឹកមេរៀន**<br>១. តើប្រភពនៃការបំពុលតំបន់ឆ្នេរមានប៉ុន្មាន?<br>២. យោងលើប្រភពនៃការបំពុលតំបន់ឆ្នេរតើគេអាចចែកសារជាតុបំពុលជា ប៉ុន្មានផ្នែក? អ្វីខ្លះ? | ព្រោះនៅទីនោះសកម្មភាពមនុស្សមានភាពមមាញឹក។<br>**សំណួររំលឹកមេរៀន**<br>១. ប្រភពនៃការបំពុលតំបន់ឆ្នេរមាន ៤ ប្រភព។<br>២. យោងលើប្រភពនៃការបំពុលតំបន់ឆ្នេរគេអាចចែកសារជាតុបំពុលជា ៣ ផ្នែក ។ គឺ ៖<br>- សារជាតុពុលក្នុងកាកសំណល់ឧស្សាហកម្ម<br>- សារជាតុពុលក្នុងកាកសំណល់កសិកម្ម<br>- សារជាតុពុលក្នុងកាកសំណល់លំនៅស្ថាន ។ | |
| **ជំហានទី៣៖ មេរៀនថ្មី (៣០នាទី)** | | |
| **១. ការយល់ពីបញ្ហា និងបង្ហាញសេណារីយ៉ូ (៥ នាទី)**<br>- បង្ហាញរូបភាព ឬទិន្នន័យខ្លីមួយអំពីការធ្លាក់ចុះគុណភាពខ្យល់។ | **ជំពូកទី៤៖ កង្វក់និងការត្រួតពិនិត្យ**<br><br>**មេរៀនទី១៖ កង្វក់បរិយាកាស**<br>១. កំណើនប្រជាជន | - ត្រៀមខ្លួនសិក្សាមេរៀនបន្ត<br>- សិស្សសង្កេតមើលរូបភាព និងទិន្នន័យដោយយកចិត្តទុកដាក់ |

| | | |
|---|---|---|
| - **ដាក់សេណារីយ៉ូបញ្ហា៖**<br>*"ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះទីក្រុងរបស់យើងមានការអភិវឌ្ឍយ៉ាងឆាប់រហ័សដែលអមដោយកំណើនប្រជាជនការដ្ឋានសាងសង់និងចរាចរណ៍កកស្ទះ។ក្នុងនាមជាមន្ត្រីបរិស្ថានវ័យក្មេង មួយរូប តើអ្នកអាចវិភាគរកមូលហេតុ និងប្រភពចម្បងៗដែលធ្វើឱ្យខ្យល់បាត់បង់ភាពបរិសុទ្ធបានដោយរបៀបណា?"* | ២. ស្ថានភាពបរិយាកាស<br>៣. ប្រភេទនៃកង្វក់អាកាស<br>៤. ប្រភពនៃកង្វក់អាកាស<br>**បញ្ហាគោល៖**<br>ការស្វែងរកទំនាក់ទំនងរវាងកំណើនប្រជាជន សកម្មភាពមនុស្ស និងកង្វក់អាកាស។<br> | -សិស្សអានសេណារីយ៉ូបញ្ហាដែលគ្រូបានដាក់ឱ្យ<br>- សិស្សកំណត់តួនាទីរបស់ខ្លួន (ជាមន្ត្រីបរិស្ថាន) |
| ២. ការវិភាគបញ្ហា (Think - ៥ នាទី)<br>- ណែនាំសិស្សឱ្យគិតរៀងៗខ្លួនដើម្បីទាញយកពាក្យគន្លឹះពីសេណារីយ៉ូ។<br>- ឱ្យសិស្សកំណត់ថា **"តើមានអ្វីខ្លះដែលយើងដឹងហើយ?"** និង **"តើមានអ្វីខ្លះដែលយើងត្រូវស្រាវជ្រាវ** | **ការកំណត់ពាក្យគន្លឹះ និងតម្រូវការចាំបាច់៖**<br>- និយមន័យកង្វក់អាកាស និងបរិយាកាស<br>- កត្តាបង្ក (ធម្មជាតិ និង មនុស្ស)<br>- ប្រភពនៃការបំពុល (យានយន្ត រោងចក្រ...)<br>- ឥទ្ធិពលនៃកំណើនប្រជាជន | - សិស្សគិតម្នាក់ឯង (Think) រួចកត់ត្រាពាក្យគន្លឹះទៅក្នុងសៀវភៅ<br>- សិស្សប្រើប្រាស់សៀវភៅពុម្ពទំព័រពាក់ព័ន្ធដើម្បីស្វែងរកនិយមន័យ ឬស្រាវជ្រាវតាម Internet |

| | | |
|---|---|---|
| បន្ថែម?" | | |
| **៣. ការសហការដោះស្រាយបញ្ហា (Pair - ១០ នាទី)**<br><br>- ឱ្យសិស្សចាប់គូ (Pair) ពិភាក្សាគ្នាដើម្បីប្រមូលព័ត៌មានពីសៀវភៅពុម្ពមកឆ្លើយតបនឹងសេណារីយ៉ូ។<br><br>- ដើរសម្របសម្រួល (Scaffolding) និងចោទសួរជាសំណួរបំផុសៈ *"តើកំណើនប្រជាជន និងការកកស្ទះចរាចរណ៍ក្នុងសេណារីយ៉ូមានទំនាក់ទំនងអ្វីនឹងកង្វក់ អាកាស?"* | **ការឆ្លើយតបសេណារីយ៉ូៈ**<br><br>**១. កង្វក់អាកាស**<br>គឺវត្តមានសារធាតុគ្រោះថ្នាក់ក្នុងខ្យល់ (ឧស្ម័ន ធូលីល្អិត)។<br><br>**២. មូលហេតុ និងប្រភពៈ**<br>- **សកម្មភាពមនុស្សៈ** ផ្សែងយានយន្ត ការដ្ឋានសំណង់ រោងចក្រ ការដុតសំរាម...<br>- **ធម្មជាតិៈ** ភ្លើងឆេះព្រៃ បន្ទុះភ្នំភ្លើង...<br>៣. **ទំនាក់ទំនងៈ**<br>កំណើនប្រជាជនទាមទារការប្រើប្រាស់ថាមពល និងយានយន្តខ្ពស់ ដែលបញ្ចេញសារធាតុពុលកាន់តែច្រើន។ | -សិស្សពិភាក្សាជាដៃគូផ្លាស់ប្តូរគំនិតគ្នា<br>- សិស្សភ្ជាប់ទ្រឹស្តីក្នុងសៀវភៅទៅនឹងសេណារីយ៉ូជាក់ស្តែង<br><br>- សិស្សសរសេរចម្លើយរួមមួយជាលទ្ធផលនៃការដោះស្រាយបញ្ហា |
| **៤.ការចែករំលែកនិងវាយតម្លៃចម្លើយ (Share - ១២ នាទី)**<br><br>- ប្រើកម្មវិធី Flippity ដើម្បីចាប់ឈ្មោះសិស្សឡើងធ្វើបទបង្ហាញខ្លីពីរបកគំហើញរបស់ពួកគេ។ | **ការសន្និដ្ឋានរួមៈ**<br><br>កង្វក់អាកាសកើតឡើងដោយសារកត្តា២ធំៗ គឺធម្មជាតិ និងសកម្មភាពមនុស្ស។ កំណើនប្រជាជនគឺជាកាតាលីករជំរុញឱ្យសកម្មភាពឧស្សាហកម្ម និងបម្រើបម្រាស់យានយន្តកើនឡើង ដែលជាប្រភពចម្បងនៃការបញ្ចេញសារជា | - តំណាងក្រុមដែលត្រូវឈ្មោះឡើងធ្វើបទបង្ហាញ |

| | | |
|---|---|---|
| https://flippity.net/<br>- បំផុសឱ្យសិស្សផ្សេងទៀតផ្តល់មតិយោបល់។<br>- គ្រូធ្វើសំយោគ និងសន្និដ្ឋានខ្លឹមសាររួម ដោយភ្ជាប់ទៅនឹងផ្ទាំងរូបភាពភ្នាក់ងារបំពុលបរិយាកាស។ | តុពុលទៅក្នុងបរិយាកាស។<br> | - សិស្សក្នុងថ្នាក់យកចិត្តទុកដាក់ស្តាប់ ផ្ទៀងផ្ទាត់ចម្លើយ និងកត់ត្រាចំណុចខ្វះខាត<br>- សិស្សកត់ត្រាសេចក្តីសន្និដ្ឋានរួមចូលក្នុងសៀវភៅ |
| **ជំហានទី៤៖ ពង្រឹងពុទ្ធិ (៤នាទី)** | | |
| - **សួរសំណួរ៖**<br>១. ហេតុអ្វីបានជាគេនិយាយថា កំណើនប្រជាជននាំឱ្យមានកំណើនកង្វក់អាកាស?<br>២. តើកង្វក់អាកាសបណ្តាលមកពីកត្តាអ្វីខ្លះ? | ១. កំណើនប្រជាជននាំឱ្យមានកំណើនកង្វក់អាកាសព្រោះថាកំណើនប្រជាជនទាមទារឱ្យមានការបង្កើន ៖<br>- ការប្រើប្រាស់យានយន្តកើនឡើង<br>- ការពង្រីកឧស្សាហកម្មផលិតកម្ម<br>- ការកាប់បំផ្លាញព្រៃឈើ<br>- ការបង្កើតកាកសំណល់<br>- ការប្រើប្រាស់ថាមពលកើនឡើង ។<br>២. កង្វក់អាកាសបណ្តាលមកពីកត្តា ២ ធំៗគឺ៖ កត្តាបាតុភូតធម្មជាតិ និងសកម្មភាពមនុស្ស ។ | - សិស្សឡើងឆ្លើយ |

| ជំហានទី៥៖ កិច្ចការផ្ទះ និងបណ្ដាំផ្ញើ ( ៤នាទី ) | | |
|---|---|---|
| - **ដាក់កិច្ចការសិស្សធ្វើនៅផ្ទះ**<br><br>១. តើកង្វក់អាកាសមានប៉ុន្មានប្រភេទអ្វីខ្លះ ? ចូរបកស្រាយពីប្រភេទនីមួយៗ។ | **កិច្ចការផ្ទះ**<br><br>១. កង្វក់អាកាសមាន ២ ប្រភេទគឺ៖<br>- **ប្រភេទទី១៖**<br>កង្វក់អាកាសខាងក្រៅស្ដែងចេញដោយការបម្លាស់ទីក្នុងបរិយាកាសនៃកម្ទេចភាគល្អិតៗនិងឧស្ម័នផ្ទុកសារធាតុដែលអណ្ដែតលើផ្ទៃផែនដី ។<br>- **ប្រភេទទី២៖**<br>កង្វក់អាកាសខាងក្នុងអាគារស្ដែងចេញដោយដង្ហើមបញ្ចេញក្លិនអាក្រក់ ផ្សែងបារី ខ្យល់វិលវល់ក្នុងម៉ាស៊ីនត្រជាក់ ឧស្ម័នវិទ្យុសកម្ម...។<br><br>**បណ្ដាំផ្ញើ**<br><br>-សូមប្អូនៗអានមេរៀននេះឡើងវិញ និងមើលចំណុចបន្ទាប់ផងពេលត្រឡប់ទៅផ្ទះ។<br>-រាល់ការធ្វើដំណើរត្រូវគោរពច្បាប់ចរាចរណ៍ជានិច្ច។ | - សិស្សចម្លងដាក់សៀវភៅ |

# កិច្ចតែងការបង្រៀន

**មុខវិជ្ជា៖ ជីវវិទ្យា**

**ជំពូកទី៣ ៖** មេរោគ និងជំងឺឆ្លង

**មេរៀនទី២ ៖** ជំងឺឆ្លងតាមប្រព័ន្ធរំលាយអាហារ (ជំងឺអាសន្នរោគ)

**បង្រៀនថ្នាក់ទី ៖** ថ្នាក់ទី១០

**រយៈពេល ៖** ៤៥នាទី (ម៉ោងទី១)

**វត្ថុបំណងមេរៀន**

ក្រោយពីសិក្សាមេរៀននេះចប់សិស្សមានលទ្ធភាព៖

- **វិជ្ជាសម្បទា ៖** រៀបរាប់ពីរោគសញ្ញា និងមូលហេតុចម្លងនៃជំងឺអាសន្នរោគបានយ៉ាងច្បាស់លាស់ តាមរយៈការសិក្សាស្រាវជ្រាវក្នុងក្រុមជំនាញ។
- **បំណិនសម្បទា ៖** វិភាគរកប្រភពនៃការចម្លងជំងឺនៅក្នុងសហគមន៍ និងទាញរកដំណោះស្រាយរួម តាមរយៈការពិភាក្សាផ្គុំព័ត៌មាន (Jigsaw) ដោះស្រាយសេណារីយ៉ូបញ្ហាបានយ៉ាងត្រឹមត្រូវ។
- **ចរិយាសម្បទា ៖** បណ្តុះស្មារតីសិស្សឱ្យមានទម្លាប់ថែរក្សាអនាម័យចំណីអាហារ ទឹកផឹក និងចូលរួមអប់រំសុខភាពដល់គ្រួសារ។

**ខ្លឹមសារមេរៀន**

១. និយមន័យ និងរោគសញ្ញានៃជំងឺអាសន្នរោគ

២. មូលហេតុ និងប្រភពចម្លងរោគ

៣. វិធានការការពារ និងទប់ស្កាត់

**សម្ភារឧបទ្ទេស**

- **សម្ភារៈគ្រូ ៖** រូបភាព ឬវីដេអូខ្លីពីសហគមន៍រងគ្រោះដោយទឹកជំនន់, LCD projector, Slide, សន្លឹកកិច្ចការ, កម្មវិធី Random Name Picker ។
- **សម្ភារៈសិស្ស ៖** សៀវភៅពុម្ពជីវវិទ្យាថ្នាក់ទី១០, សៀវភៅកត់ត្រា, ប៊ិចខៀវ ក្រហម, សន្លឹកកិច្ចការ។

**វិធីសាស្ត្របង្រៀន**

- **គោលវិធីបង្រៀន ៖** ការសិក្សាតាមបែបស្ថាបនានិយម
- **វិធីសាស្ត្របង្រៀន ៖** បែបដោះស្រាយបញ្ហា ( PBL )
- **បច្ចេកទេសបង្រៀន ៖** បច្ចេកទេស Jigsaw ( ការផ្គុំរូប )

ដំណើរកិច្ចតែងការបង្រៀន

| **សកម្មភាពគ្រូ** | **ខ្លឹមសារមេរៀន** | **សកម្មភាពសិស្ស** |
|---|---|---|
| | ជំហានទី១៖ លំនឹងថ្នាក់ ( ៣នាទី )<br>**រដ្ឋបាលថ្នាក់រៀន** | |
| - ពិនិត្យអវត្តមាន<br>- ពិនិត្យអនាម័យ ឯកសណ្ឋាន និងសណ្ដាប់ធ្នាប់ | **រដ្ឋបាលថ្នាក់រៀន** | - ប្រធានថ្នាក់រាយការណ៍អវត្តមាន<br>- សិស្សរៀបចំខ្លួន និងសណ្ដាប់ធ្នាប់ |
| | ជំហានទី២៖ កែកិច្ចការផ្ទះ និងរំលឹកមេរៀន ( ៤នាទី )<br>**កិច្ចការផ្ទះ និងសំណួររំលឹក** | |
| - **កែកិច្ចការផ្ទះ៖** តើមេរោគអាចឆ្លងចូលក្នុងរាងកាយមនុស្សតាមផ្លូវណាខ្លះ ?<br>- **សំណួររំលឹក៖** | ចម្លើយរំពឹងទុក៖<br>- ផ្លូវដង្ហើម ផ្លូវរំលាយអាហារ និងតាមស្បែក ឬការប៉ះពាល់... | - សិស្សឡើងកែកិច្ចការផ្ទះ |

| | | |
|---|---|---|
| តើជំងឺអ្វីខ្លះដែលប្អូនធ្លាប់ជួបប្រទះញឹកញាប់ជាងគេនៅរដូវវស្សា? | - ជំងឺគ្រុនឈាម ជំងឺរាករូស... | - សិស្សចូលរួមឆ្លើយសំណួររំលឹក |
| **ជំហានទី៣៖ មេរៀនថ្មី (៣០នាទី)**<br>**មេរៀនទី២៖ ជំងឺឆ្លងតាមប្រព័ន្ធរំលាយអាហារ** | | |
| ១. ការយល់ពីបញ្ហា និងបង្ហាញសេណារីយ៉ូ (៥នាទី)<br><br>- បង្ហាញរូបភាពស្ថានភាពភូមិមួយលិចទឹក។<br>- **ដាក់សេណារីយ៉ូ៖** *"ភូមិ 'ក' ទើបតែរងគ្រោះដោយទឹកជំនន់។ ស្រាប់តែប៉ុន្មានថ្ងៃនេះ អ្នកភូមិមានអាការៈរាគរូសធ្ងន់ធ្ងរ ក្អួតចង្អោរ និងអស់កម្លាំងខ្លាំង។ ក្នុងនាមជាក្រុម'មន្ត្រីសុខាភិបាល' តើអ្នកត្រូវធ្វើការវិភាគរកប្រភពដើម និងដាក់ចេញនូវដំណោះស្រាយបន្ទាន់អ្វីខ្លះ?"* | **បញ្ហាគោល៖**<br>ការស្វែងរកប្រភពចម្លងជំងឺអាសន្នរោគក្នុងស្ថានភាពទឹកជំនន់និងការរៀបចំវិធានការទប់ស្កាត់។<br><br> | - សិស្សសង្កេតរូបភាព<br>-អាន និងស្តាប់សេណារីយ៉ូបញ្ហាដែលគ្រូបានដាក់ឱ្យ<br>- កំណត់តួនាទីខ្លួនឯង (ជាមន្ត្រីសុខាភិបាល) |

| | | |
|---|---|---|
| ២. ការបែងចែកក្រុមជំនាញ<br>( Expert Groups - ១០នាទី )<br>- បែងចែកសិស្សជាក្រុមដើម<br>( Home Groups )<br>ដែលមានសមាជិក ៤នាក់។<br>- ឱ្យសិស្សលេខរៀងដូចគ្នា<br>ចេញមកជួបគ្នាបង្កើតជា<br>**ក្រុមជំនាញ**ដើម្បីស្រាវជ្រាវចំ<br>ណុចរៀងៗខ្លួន៖<br>* ក្រុមជំនាញទី១៖<br>ស្រាវជ្រាវពីរោគសញ្ញា<br>* ក្រុមជំនាញទី២៖<br>ស្រាវជ្រាវពីមូលហេតុ( បាក់តេរី )<br>* ក្រុមជំនាញទី៣៖<br>ស្រាវជ្រាវពីប្រភពចម្លង<br>* ក្រុមជំនាញទី៤៖<br>ស្រាវជ្រាវពីដំណោះស្រាយ<br>- គ្រូដើរសម្របសម្រួល<br>( Scaffolding )<br>តាមក្រុមជំនាញនីមួយៗ។ | **ការស្រាវជ្រាវតាមផ្នែក៖**<br>សិស្សត្រូវអានសៀវភៅពុម្ពទំព័រពាក់ព័ន្ធ<br>ដើម្បីក្លាយជា "អ្នកជំនាញ"<br>លើផ្នែកដែលខ្លួនទទួលខុសត្រូវ<br>ដើម្បីត្រៀមយកទៅពន្យល់សមាជិកក្រុមដើម<br>វិញ។ | - សិស្សបំបែកចេញពី<br>ក្រុមដើមទៅអង្គុយតាមក្រុ<br>មជំនាញ<br>- សិស្សរួមគ្នាស្រាវជ្រាវ<br>និងកត់ត្រាចំណុចសំខាន់<br>ៗដែលទាក់ទងនឹងសេ<br>ណារីយ៉ូទៅតាមប្រធានប<br>ទរៀងៗខ្លួន។ |
| **៣. ការពិភាក្សាក្នុងក្រុមដើម** | **ការឆ្លើយតបសេណារីយ៉ូ** | - សិស្សត្រឡប់មកក្រុម |

| | | |
|---|---|---|
| (Home Groups - ១០នាទី)<br>- តម្រូវឱ្យសិស្សជំនាញត្រឡប់ទៅ **ក្រុមដើម** របស់ខ្លួនវិញ។<br>- ឱ្យសិស្សម្នាក់ៗប្តូរវេនគ្នាពន្យល់សមាជិកក្រុមពីអ្វីដែលខ្លួនទើបបានស្រាវជ្រាវ។<br>- ណែនាំឱ្យក្រុមដើមធ្វើសំយោគព័ត៌មានទាំង ៤ចំណែក ដើម្បីសរសេរជាដំណោះស្រាយរួមមួយឆ្លើយតបនឹងសេណារីយ៉ូបញ្ហា។ | **(លទ្ធផលរួមរបស់ក្រុម)៖**<br>- ជំងឺអាសន្នរោគ បង្កដោយបាក់តេរី Vibrio cholerae។<br>- ទឹកជំនន់ហូរនាំកាកសំណល់ចូលប្រភពទឹកប្រើប្រាស់។<br>- ដំណោះស្រាយ៖ ផឹកទឹកដាំពុះ ប្រើថ្នាំសម្លាប់មេរោគក្នុងទឹក លាងដៃ និងបញ្ជូនអ្នកជំងឺទៅមណ្ឌលសុខភាព។ | ដើមវិញ<br>- ផ្លាស់ប្តូរវេនគ្នាពន្យល់ និងចែករំលែកចំណេះដឹងដែលខ្លួនស្រាវជ្រាវបាន<br>- សមាជិកទាំងអស់សហការគ្នាសរសេរចម្លើយរួមមួយជាលទ្ធផលនៃការដោះស្រាយបញ្ហា |
| ៤. ការចែករំលែកនិងវាយតម្លៃចម្លើយ (Share - ៥នាទី)<br>- ប្រើកម្មវិធី Random Name Picker ដើម្បីចាប់ឈ្មោះសិស្សឡើងធ្វើបទបង្ហាញពីរបកគំហើញរបស់ពួកគេ។<br>- បំផុសឱ្យសិស្សផ្សេងទៀតផ្តល់មតិយោបល់។<br>- គ្រូធ្វើសំយោគនិងសន្និដ្ឋាន | **ការសន្និដ្ឋានរួម៖**<br>ជំងឺអាសន្នរោគជាជំងឺឆ្លងលឿនបង្កដោយបាក់តេរីដែលឆ្លងតាមរយៈការបរិភោគចំណីអាហារ ឬទឹកដែលមានមេរោគ។ គ្រោះធម្មជាតិ(ទឹកជំនន់) គឺជាកត្តាជំរុញឱ្យជំងឺនេះរាលដាលលឿន។ | - តំណាងក្រុមដែលត្រូវឈ្មោះឡើងធ្វើបទបង្ហាញ<br>- សិស្សក្នុងថ្នាក់យកចិត្តទុកដាក់ស្តាប់ និងផ្ទៀងផ្ទាត់ចម្លើយ<br>- សិស្សកត់ត្រាសេចក្តី |

| | | |
|---|---|---|
| ខ្លឹមសាររួម។ | | សន្និដ្ឋានរួមចូលក្នុងសៀវភៅ |
| **ជំហានទី៤៖ ពង្រឹងពុទ្ធិ (៤នាទី)** | | |
| - សួរសំណួរទៅកាន់សិស្ស ៖<br>១. តើជំងឺអាសន្នរោគបង្កឡើងដោយសារអ្វី?<br>២. តើយើងអាចទប់ស្កាត់ការឆ្លងជំងឺនេះតាមវិធីណាខ្លះ? | ១. បង្កដោយបាក់តេរី ឆ្លងតាមរយៈទឹក និងអាហារមិនស្អាត។<br>២. ទប់ស្កាត់តាមរយៈការដាំទឹកឱ្យពុះមុនផឹក លាងដៃជាមួយសាប៊ូ និងបរិភោគអាហារឆ្អិន។ | - សិស្សឡើងឆ្លើយ |
| **ជំហានទី៥ (៤នាទី)**<br>**កិច្ចការផ្ទះ និងបណ្តាំផ្ញើ** | | |
| - គ្រូដាក់**កិច្ចការផ្ទះឱ្យសិស្ស៖**<br><br>**- បណ្តាំផ្ញើ៖**<br>អនុវត្តអនាម័យជាប្រចាំនៅផ្ទះ និងសាលារៀន។ | - **កិច្ចការផ្ទះ៖**<br>ចូរស្រាវជ្រាវពីជំងឺឆ្លងតាមប្រព័ន្ធរំលាយអាហារមួយទៀត (ឧទាហរណ៍៖ ជំងឺរាកមួល) ហើយប្រៀបធៀបវាទៅនឹងជំងឺអាសន្នរោគ។<br>- **បណ្តាំផ្ញើ៖** អនុវត្តអនាម័យជាប្រចាំនៅផ្ទះ និងសាលារៀន។ | - សិស្សចម្លងកិច្ចការចូលសៀវភៅ<br><br>- សិស្សស្តាប់បណ្តាំផ្ញើ |

**គម្រូ និងរូបមន្តបង្កើតសេណារីយ៉ូបញ្ហា (GRASPS Framework)**

ដើម្បីប្រែក្លាយបញ្ហាធម្មតាទៅជាបញ្ហាជាក់ស្តែងដែលទាក់ទាញ និងជំរុញសិស្សឱ្យផ្លាស់ប្តូរពីការរៀនអសកម្មទៅជាអ្នកដោះស្រាយបញ្ហាយ៉ាងសកម្ម លោកគ្រូ អ្នកគ្រូអាចប្រើប្រាស់រូបមន្ត GRASPS ដែលត្រូវបានបង្កើតឡើងដោយលោកWigginsនិងMcTighe(2005)នៅក្នុងក្របខណ្ឌនៃការរចនាមេរៀនដែលចាប់ផ្តើមដោយការគិតពីគំនិតសំខាន់ៗដែលចង់ឱ្យសិស្សចេះ(Understanding by Design)។ ក្របខណ្ឌនេះជួយកំណត់រចនាសម្ព័ន្ធនៃបញ្ហាឱ្យមានភាពច្បាស់លាស់ស្រដៀងទៅនឹងស្ថានភាពក្នុងជីវិតពិតនិងផ្តល់គោលដៅជាក់លាក់ដល់សិស្ស។

- **G - Goal (គោលដៅ ឬបេសកកម្ម) ៖** តើបញ្ហាអ្វីដែលត្រូវដោះស្រាយ? ឬតើសិស្សមានបេសកកម្មអ្វីខ្លះ?(ឧទាហរណ៍៖ កាត់បន្ថយកាកសំណល់ប្លាស្ទិកស្វែងរកប្រភពជំងឺឆ្លងនៅក្នុងភូមិ) ។
- **R-Role (តួនាទី)៖** តើសិស្សត្រូវដើរតួជាអ្វីនៅក្នុងសេណារីយ៉ូនោះ? ការដាក់តួនាទីជួយឱ្យសិស្សមានអារម្មណ៍ទទួលខុសត្រូវខ្ពស់។ (ឧទាហរណ៍៖ មន្ត្រីបរិស្ថានវ័យក្មេង មន្ត្រីសុខាភិបាល វិស្វករ ឬអ្នកស្រាវជ្រាវ) ។
- **A-Audience (ទស្សនិកជន)៖** តើសិស្សត្រូវរាយការណ៍បញ្ចុះបញ្ចូលឬបង្ហាញលទ្ធផលទៅកាន់នរណា? ទស្សនិកជនអាចជាមនុស្សពិត ឬតួអង្គប្រឌិត។ (ឧទាហរណ៍៖ អាជ្ញាធរមូលដ្ឋាន នាយកសាលា ឬប្រជាជនក្នុងសហគមន៍) ។
- **S-Situation (ស្ថានភាពឬបរិបទ)៖** តើបរិបទនៃបញ្ហានេះកើតឡើងនៅឯណា? មានរឿងរ៉ាវអ្វីខ្លះកំពុងកើតឡើង? ទីនេះគឺជាកន្លែងដែលគ្រូត្រូវរៀបរាប់សាច់រឿងគួរឱ្យចាប់អារម្មណ៍។ (ឧទាហរណ៍៖ ភូមិមួយទើបតែរងគ្រោះដោយទឹកជំនន់ និងមានអាការៈរាគរូសផ្ទុះឡើង) ។
- **P - Product (ផលិតផល ឬដំណោះស្រាយ) ៖** តើសិស្សត្រូវបង្កើតអ្វីដើម្បីបង្ហាញពីការយល់ដឹង និងដំណោះស្រាយរបស់ពួកគេ? (ឧទាហរណ៍៖ របាយការណ៍សកម្មភាព គម្រោងស្នើសុំ **(Proposal)** ផែនទីទេសចរណ៍សហគមន៍ ឬវីដេអូខ្លីផ្សព្វផ្សាយ) ។
- **S-Standards(ស្តង់ដារឬលក្ខណៈវិនិច្ឆ័យវាយតម្លៃ)៖** តើគ្រូឬទស្សនិកជននឹងវាយតម្លៃលទ្ធផលនោះផ្អែកលើលក្ខណៈវិនិច្ឆ័យអ្វីខ្លះ? (ឧទាហរណ៍៖វាយតម្លៃលើភាពត្រឹមត្រូវនៃទិន្នន័យការសហការក្រុម និង ភាពច្នៃប្រឌិតនៃការធ្វើបទបង្ហាញ) ។




**ទម្រង់គំរូបង្កើតសេណារីយ៉ូ (Scenario Design Template)**

លោកគ្រូ អ្នកគ្រូអាចចថតចម្លងនិងបំពេញចន្លោះនៅក្នុងតារាងខាងក្រោមដើម្បីរចនាសេណារីយ៉ូបញ្ហាផ្ទាល់ខ្លួនសម្រាប់មុខវិជ្ជាណាមួយក៏បាន៖

| ជាតុផ្សំនៃ GRASPS | សំណួរតម្រង់ទិសសម្រាប់គ្រូ | ការរៀបចំរបស់គ្រូ (សរសេរបំពេញទីនេះ) |
|---|---|---|
| **Goal** (គោលដៅ) | តើសិស្សត្រូវសម្រេចគោលដៅ ឬបេសកកម្មអ្វី? | |

| | | |
|---|---|---|
| **Role** ( តួនាទី ) | តើសិស្សនឹងត្រូវដើរតួជាអ្នកណា ? | |
| **Audience** ( ទស្សនិកជន ) | តើសិស្សត្រូវរាយការណ៍ ឬបង្ហាញដំណោះស្រាយទៅនរណា ? | |
| **Situation** ( ស្ថានភាព ) | តើបញ្ហានេះមានសាច់រឿង ឧបសគ្គ ឬបរិបទបែបណា ? | |
| **Product** (ផលិតផល ) | តើសិស្សត្រូវបង្កើតអ្វីជាលទ្ធផលចុងក្រោយ ? | |
| **Standards** ( ស្តង់ដារ ) | តើលទ្ធផលត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ? | |

### ឧទាហរណ៍នៃការអនុវត្តរូបមន្ត GRASPS ជាក់ស្តែង

*( ដកស្រង់ចេញពីគំរូកិច្ចតែងការបង្រៀនមុខវិជ្ជាភូមិវិទ្យា៖ កង្វក់បរិយាកាស )*

- **Goal៖** វិភាគរកមូលហេតុ និងប្រភពចម្បងៗដែលធ្វើឱ្យខ្យល់ក្នុងទីក្រុងបាត់បង់ភាពបរិសុទ្ធ ។
- **Role៖** សិស្សដើរតួជា "មន្ត្រីបរិស្ថានវ័យក្មេង" ។
- **Audience៖** ក្រុមប្រឹក្សាក្រុង ( តំណាងដោយលោកគ្រូ អ្នកគ្រូ និងមិត្តរួមថ្នាក់ ) ។
- **Situation៖** ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទីក្រុងមានការអភិវឌ្ឍយ៉ាងឆាប់រហ័ស

ដែលអមដោយកំណើនប្រជាជន ការដ្ឋានសាងសង់ និងចរាចរណ៍កកស្ទះ ។

- **Product៖** ធ្វើបទបង្ហាញខ្លីមួយ ដើម្បីណែនាំពីវិធានការកាត់បន្ថយកង្វក់អាកាស។
- **Standards៖** ត្រូវពន្យល់ឱ្យបានច្បាស់ពីទំនាក់ទំនងរវាងកំណើនប្រជាជន និងកង្វក់អាកាស ដោយផ្អែកលើខ្លឹមសារមេរៀន ។

### សេណារីយ៉ូ៖

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទីក្រុងរបស់យើងមានការអភិវឌ្ឍយ៉ាងឆាប់រហ័សដែលអមដោយកំណើនប្រជាជន ការដ្ឋានសាងសង់ និងចរាចរណ៍កកស្ទះ **(Situation)**។ ក្នុងនាមអ្នកជាមន្ត្រីបរិស្ថានវ័យក្មេង **(Role)** អ្នកមានភារកិច្ចវិភាគរកមូលហេតុ និងប្រភពចម្បងៗដែលធ្វើឱ្យខ្យល់បាត់បង់ភាពបរិសុទ្ធ **(Goal)**។ សូមធ្វើ ការជាក្រុមដើម្បីរៀបចំបទបង្ហាញមួយ **(Product)** ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាក្រុង **(Audience)**។ បទបង្ហាញរបស់អ្នកនឹងត្រូវបានវាយតម្លៃទៅលើភាពត្រឹមត្រូវនៃការភ្ជាប់ទំនាក់ទំនងរវាងកំណើនប្រជាជន និងកង្វក់អាកាស **(Standards)** ។

## ការប្រើប្រាស់បញ្ញាសិប្បនិម្មិត (Generative AI) ដើម្បីរចនាសេណារីយ៉ូបញ្ហា GRASPS

នៅក្នុងយុគសម័យឌីជីថល លោកគ្រូអ្នកគ្រូអាចចំណេញពេលវេលានិងទទួលបានគំនិតច្នៃប្រឌិតថ្មីៗយ៉ាងច្រើន តាមរយៈការប្រើប្រាស់ឧបករណ៍បញ្ញាសិប្បនិម្មិត (ដូចជា **Gemini, ChatGPT** ឬ **Copilot**) ដើម្បីជាជំនួយការក្នុងការរចនាសេណារីយ៉ូបញ្ហា។

### ក. ឧទាហរណ៍ជាក់ស្តែងក្នុងការបញ្ចូលឃ្លាបញ្ជា (Prompt) ទៅកាន់ AI

ឧបមាថាលោកគ្រូអ្នកគ្រូបង្រៀនមុខវិជ្ជាផែនដីនិងបរិស្ថានវិទ្យាថ្នាក់ទី១០ហើយចង់ឱ្យសិស្សធ្វើគម្រោងស្តី ពីការគ្រប់គ្រងសំណល់ប្លាស្ទិក។ លោកគ្រូអ្នកគ្រូអាចសរសេរ Prompt ដូចខាងក្រោម៖

**"សូមដើរតួជាអ្នកជំនាញផ្នែកអប់រំ និងអ្នករចនាកម្មវិធីសិក្សា។ សូមជួយបង្កើតសេណារីយ៉ូវាយតម្លៃការអនុវត្តមួយសម្រាប់សិស្សថ្នាក់ទី១០ លើមុខវិជ្ជាផែនដី និងបរិស្ថានទាក់ទងនឹងប្រធានបទការកាត់បន្ថយសំណល់ប្លាស្ទិកនៅក្នុងសាលារៀន។ សូមប្រើប្រាស់រូបមន្ត GRASPS ដើម្បីរៀបចំសេណារីយ៉ូនេះដោយរៀបរាប់ឱ្យបានច្បាស់លាស់នូវ Goal, Role, Audience, Situation, Product, និង Standards។"**

### ខ. លទ្ធផលដែល AI អាចនឹងឆ្លើយតប (Expected Output)

នៅពេលដែលលោកគ្រូអ្នកគ្រូបញ្ចូល Prompt ខាងលើ AI នឹងផ្តល់លទ្ធផលយ៉ាងមានរបៀបរៀបរយដូចខាងក្រោម៖

- G - Goal (គោលដៅ): គោលដៅរបស់អ្នកគឺត្រូវរចនា និងស្នើឡើងនូវ "យុទ្ធនាការកាត់បន្ថយប្លាស្ទិក" ដើម្បីកាត់បន្ថយការប្រើប្រាស់ថង់ និងដបប្លាស្ទិកនៅក្នុងបរិវេណសាលារៀនឱ្យបានយ៉ាងហោចណាស់ ៥០% ក្នុងរយៈពេល ៣ខែ។
- R - Role (តួនាទី): អ្នកដើរតួជាប្រធានក្លឹបយុវជនបរិស្ថាន ប្រចាំសាលារៀន ដែលមានភារកិច្ចដឹកនាំ និងស្វែងរកដំណោះស្រាយបញ្ហាបរិស្ថាន។
- A - Audience (ទស្សនិកជន): ទស្សនិកជនគោលដៅរបស់អ្នកគឺ នាយកសាលា គណៈកម្មការសាលា និងសិស្សានុសិស្ស ដែលអ្នកត្រូវបញ្ចុះបញ្ចូលឱ្យចូលរួមក្នុងយុទ្ធនាការនេះ។
- S - Situation (ស្ថានភាព): បច្ចុប្បន្ននេះ ធុងសំរាមនៅក្នុងសាលារៀនពោរពេញទៅដោយដបទឹក និងថង់ចំណីអាហារប្លាស្ទិកដែលសិស្សប្រើប្រាស់រួច។ នាយកសាលារៀនកំពុងប្រឈមនឹងការចំណាយខ្ពស់លើការគ្រប់គ្រងសំរាមហើយវាធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាពសាលា។ នាយកសាលាកំពុងស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធភាព និងអាចអនុវត្តបានពិតប្រាកដ។
- P - Product (ផលិតផល): អ្នកត្រូវបង្កើតលទ្ធផលចំនួន២៖ ផែនការសកម្មភាព (Action Plan) ឯកសារសំណើគម្រោងលម្អិតចំនួន ២ទំព័រ ដែលបង្ហាញពីសកម្មភាពជាក់ស្តែង តម្រូវការថវិកា និងកាលវិភាគ។ ផ្ទាំងរូបភាពផ្សព្វផ្សាយ (Poster) ឬវីដេអូខ្លី(១នាទី) សម្រាប់អប់រំនិងទាក់ទាញសិស្សផ្សេងទៀតឱ្យចូលរួមផ្លាស់ប្តូរទម្លាប់។
- S-Standards(ស្តង់ដារវាយតម្លៃ): គម្រោងរបស់អ្នកនឹងត្រូវវាយតម្លៃដោយផ្អែកលើ៖
  - ភាពសមហេតុផលនិងអាចអនុវត្តបាន៖ផែនការមានភាពប្រាកដនិយម។
  - ការយល់ដឹងពីបរិស្ថានដោយបង្ហាញពីផលប៉ះពាល់នៃប្លាស្ទិកបានច្បាស់លាស់ដោយផ្អែកលើមេរៀនដែលបានរៀន។
  - ភាពច្នៃប្រឌិត និងភាពទាក់ទាញដោយមានផ្ទាំងរូបភាពឬវីដេអូមានគំនិតច្នៃប្រឌិតនិងអាចទាក់ទាញ ចំណាប់អារម្មណ៍ទស្សនិកជនបានល្អ។

❋ **ចំណាំ៖** *រាល់ព័ត៌មានដែលទទួលបានពីការប្រើប្រាស់បញ្ញាសប្បនិម្មិត (AI) អាចមានកំហុស។ ដូច្នេះ លោកគ្រូ អ្នកគ្រូគួរអានត្រួតពិនិត្យ និងកែសម្រួលព័ត៌មានមុននឹងយកវាទៅបង្រៀនសិស្សដើម្បីធានាបាននូវសុពលភាព និងភាពជឿទុកបាននៃខ្លឹមសារ។*

**គំរូនិទ្ទេសបទវាយតម្លៃការងារក្រុម (Group Work Rubric)**

*គ្រូអាចប្រើសម្រាប់សង្កេត និងវាយតម្លៃដំណើរការសហការរបស់សិស្សក្នុងអំឡុងពេលដោះស្រាយបញ្ហា។*

| លក្ខណៈវិនិច្ឆ័យ | ល្អណាស់ (៤ពិន្ទុ) | ល្អ (៣ពិន្ទុ) | មធ្យម (២ពិន្ទុ) | គួរកែលម្អ (១ពិន្ទុ) |
|---|---|---|---|---|
| ការសហការ និងការចូលរួម | ចូលរួមយ៉ាងសកម្មបំផុតជំរុញអ្នកដទៃឱ្យចូលរួមនិងជួយសម្របសម្រួលដោះស្រាយបញ្ហាក្នុងក្រុម។ | ចូលរួមបានល្អផ្ដល់យោបល់ជាប្រចាំនិងសហការបានយ៉ាងរលូនជាមួយសមាជិកដទៃ។ | ចូលរួមខ្លះៗតែភាគច្រើនរង់ចាំការណែនាំឬការជំរុញពីអ្នកដទៃទើបចាប់ផ្ដើមធ្វើ។ | មិនសូវចូលរួមមិនសហការឬទុកបន្ទុកការងារទាំងអស់ឱ្យសមាជិកផ្សេងជាអ្នកធ្វើ។ |
| ការស្ដាប់ និងគោរពមតិអ្នកដទៃ | ស្ដាប់ដោយយកចិត្តទុកដាក់ខ្ពស់ឱ្យតម្លៃរាល់មតិយោបល់និងចេះសម្របសម្រួលគំនិតដែលខុសគ្នា។ | ស្ដាប់និងទទួលយកមតិយោបល់ពីសមាជិកក្រុមដោយការគោរពនិងបើកចំហរ ។ | ជួនកាលស្ដាប់ជួនកាលរំខានអ្នកដទៃឬបង្ហាញការលំបាកក្នុងការទទួលយកមតិផ្ទុយ។ | មិនស្ដាប់មតិអ្នកដទៃប្រកាន់តែមតិខ្លួនឯងឬរំខានពេលអ្នកដទៃកំពុងនិយាយ។ |
| ការបែងចែក និងទទួលខុសត្រូវភារកិច្ច | ស្ម័គ្រចិត្តទទួលការងារធ្វើរួចរាល់មុនកាលកំណត់និងមានគុណភាពខ្ពស់គួរជាទីទុកចិត្ត។ | ទទួលយកការងារដែលបានបែងចែកនិងបំពេញភារកិច្ចបានរួចរាល់ទាន់ពេលវេលា។ | ធ្វើកិច្ចការដែលបានបែងចែកបានខ្លះតែត្រូវការពញ្ញាក់ស្មារតីឬរំលឹកជាញឹកញាប់។ | មិនបំពេញការងារដែលបានបែងចែកឬធ្វើមិនទាន់ពេលវេលាដែលរំខានដល់លទ្ធផលក្រុម។ |

**គំរូនិទ្ទេសបទបង្ហាញ និងដំណោះស្រាយ** **(Presentation & Solution Rubric)**

*ប្រើដោយគ្រូ (ឬអាចឱ្យសិស្សវាយតម្លៃសិស្ស) នៅពេលក្រុមឡើងធ្វើបទបង្ហាញពីលទ្ធផលនៃការដោះស្រាយសេណារីយ៉ូ។*

| លក្ខណៈវិនិច្ឆ័យ | ល្អណាស់ (៤ពិន្ទុ) | ល្អ (៣ពិន្ទុ) | មធ្យម (២ពិន្ទុ) | ត្រូវកែលម្អ (១ពិន្ទុ) |
|---|---|---|---|---|
| **ភាពច្នៃប្រឌិតនៃដំណោះស្រាយ** | ដំណោះស្រាយមានភាពថ្មីប្លែកឆ្លើយតបចំបញ្ហាដើម ១០០%និងអាចយកទៅអនុវត្តបានជាក់ស្តែង។ | ដំណោះស្រាយល្អឆ្លើយតបនឹងបញ្ហាភាគច្រើននិងមានលក្ខណៈជាក់ស្តែងអាចទទួលយកបាន។ | ដំណោះស្រាយជាទូទៅធម្មតាឆ្លើយតបបញ្ហាបានខ្លះតែហាក់ពិបាកក្នុងការយកទៅអនុវត្ត។ | ដំណោះស្រាយមិនច្បាស់លាស់មិនពាក់ព័ន្ធនឹងបញ្ហាឬវើវាយមិនអាចអនុវត្តបាន។ |
| **ការពន្យល់ហេតុផលនិងអំណះអំណាង** | មានអំណះអំណាងរឹងមាំប្រើប្រាស់ទិន្នន័យស្រាវជ្រាវច្បាស់លាស់និងពន្យល់បានក្បោះក្បាយបំផុត។ | មានការពន្យល់ហេតុផលសមស្រប និងផ្អែកលើលទ្ធផលនៃការស្រាវជ្រាវបានត្រឹមត្រូវ។ | ការពន្យល់ហេតុផលនៅមានកម្រិតមិនសូវស៊ីជម្រៅ ឬខ្វះភស្តុតាងស្រាវជ្រាវមកគាំទ្រ។ | មិនមានអំណះអំណាងច្បាស់លាស់ឆ្លើយដោយស្មានៗ ឬមិនបានផ្អែកលើការស្រាវជ្រាវសោះ។ |
| **ជំនាញក្នុងការធ្វើបទបង្ហាញ** | និយាយច្បាស់ៗប្រើកាយវិការល្អសម្លឹងមើលអ្នកស្តាប់ទាក់ទាញនិងឆ្លើយ | និយាយបានច្បាស់លាស់មានភាពជឿជាក់និងអាចឆ្លើយសំណួរបានភាគ | និយាយរាងស្ទាក់ស្ទើរអានពីសន្លឹកក្រដាសឬSlideច្រើនជាងការសម្លឹងមើល | និយាយមិនច្បាស់គ្មានទំនាក់ទំនងភ្នែកជាមួយអ្នកស្តាប់និងមិនអាចឆ្លើយ |

| | | | | |
|---|---|---|---|---|
| | សំណួរបានយ៉ាងល្អ។ | ច្រើនដោយរលូន។ | ទៅអ្នកស្ដាប់។ | សំណួរបាន។ |

**មតិយោបល់បន្ថែម៖**

..........................................................................................................................................

.........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

## ទម្រង់វាយតម្លៃមិត្តភក្តិ (Peer Assessment Form)

*ទម្រង់នេះគ្រូអាចថតចម្លងចែកជូនសិស្សម្នាក់ៗ ដើម្បីវាយតម្លៃសមាជិកក្នុងក្រុមរបស់ខ្លួនជាសម្ងាត់។ ការធ្វើបែបនេះជួយកាត់បន្ថយភាពអសកម្ម (Free-Riding) របស់សិស្សមួយចំនួនយ៉ាងមានប្រសិទ្ធភាព។*

**ទម្រង់វាយតម្លៃសមាជិកក្រុម**

- **ឈ្មោះអ្នកវាយតម្លៃ៖** ..................................................... **ក្រុមទី៖** ...........................
- **ប្រធានបទ / ចំណងជើងគម្រោង៖** ..........................................................................

**សេចក្ដីណែនាំ៖** សូមវាយតម្លៃសមាជិកក្រុមរបស់អ្នកនីមួយៗដោយស្មោះត្រង់ទៅតាមទិដ្ឋភាពខាងក្រោម។ សូមដាក់ពិន្ទុពី ១ ដល់ ៥ ដែលក្នុងនោះ៖

*(១ = ខ្សោយបំផុត, ២ = ខ្សោយ, ៣ = មធ្យម, ៤ = ល្អ, ៥ = ល្អណាស់)*

| ល.រ | ឈ្មោះសមាជិកក្នុងក្រុម | ការចូលរួមផ្ដល់គំនិត និងស្រាវជ្រាវ (១-៥) | ការស្ដាប់ និងគោរពមតិអ្នកដទៃ (១-៥) | ការទទួលខុសត្រូវលើការងារដែលបានបែងចែក (១-៥) | ពិន្ទុសរុប (១៥) |
|---|---|---|---|---|---|
| ១ | (ឈ្មោះខ្លួនឯង) : | | | | |
| ២ | | | | | |
| ៣ | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៤ | | | | | |
| ៥ | | | | | |

**មតិយោបល់បន្ថែម៖**

១. តើអ្វីជាចំណុចខ្លាំងបំផុតរបស់ក្រុមអ្នកក្នុងការដោះស្រាយបញ្ហានេះ ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

២. តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងក្រុម ហើយអ្នកគិតថាលើកក្រោយគួរកែលម្អត្រង់ចំណុចណា ?

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

## ធនធានសម្រាប់សិក្សាស្វែងយល់បន្ថែម (Additional resources)

- https://teaching.cornell.edu/teaching-resources/active-collaborative-learning/problem-based-learning
- https://cefcambodia.com/2023/09/18/problem-based-learning-benefits-challenges-and-the-way-forward/
- https://www.cambridge.org/elt/blog/2026/03/10/problem-based-learning-a-powerful-route-to-sustainability-and-language-development/
- https://www.queensu.ca/ctl/resources/instructors/instructional-strategies/problem-based-learning
- https://youtu.be/9XQeTDZRvWI?si=ajIjNy1KfiyGZNLb

Scan ទីនេះដើម្បីទស្សនាវីដេអូណែនាំបន្ថែម

## ឯកសារយោង (References)


Barrows, H. S. (1996). Problem-based learning in medicine and beyond: A brief overview. *New Directions for Teaching and Learning, 1996*(68), 3–12.

Bonwell, C. C., & Eison, J. A. (1991). *Active Learning: Creating Excitement in the Classroom. ASHE-ERIC Higher Education Report No. 1*. George Washington University.

Brookhart, S. M. (2013). *How to create and use rubrics for formative assessment and grading*. ASCD.

Hmelo-Silver, C. E. (2004). Problem-based learning: What and how do students learn? *Educational Psychology Review, 16*(3), 235–266.

Nilson, L. B. (2010). *Teaching at its best: A research-based resource for college instructors* (3rd ed.). Jossey-Bass.

Nilson, L. B. (2010). *Teaching at its best: A research-based resource for college instructors* (3rd ed.). Jossey-Bass.

Savery, J. R. (2006). Overview of problem-based learning: Definitions and distinctions. *Interdisciplinary Journal of Problem-Based Learning, 1*(1), 9–20.

Vygotsky, L. S. (1978). *Mind in society: The development of higher psychological processes*. Harvard University Press.

Wiggins, G., & McTighe, J. (2005). *Understanding by Design* (2nd ed.). Association for Supervision and Curriculum Development (ASCD).

## អំពីអ្នកនិពន្ធ៖

បច្ចុប្បន្នលោកគ្រូ **អោក ណេត** គឺជាគ្រូឧទ្ទេសវិធីសាស្រ្តបង្រៀននៅ **ដេប៉ាតឺម៉ង់ស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី** (NGPRD) នៃវិទ្យាស្ថានជាតិអប់រំ (NIE)។ មុនពេលកាន់តួនាទីនេះលោកធ្លាប់បានបម្រើការជាគ្រូប្រឹក្សាគរុកោសល្យនៅ **វិទ្យាល័យព្រះស៊ីសុវត្ថិ** សាលារៀនជំនាន់ថ្មីអស់រយៈពេល០៣ឆ្នាំ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសអប់រំប្រឹក្សាគរុកោសល្យ ហើយក៏ជាអ្នកនិពន្ធនៃសៀវភៅ **«ការសិក្សាបែបសកម្ម (Active Learning)»** ផងដែរ ។ សៀវភៅនេះត្រូវបានសរសេរឡើងដើម្បីសម្រេចនូវគោលបំណងសំខាន់ៗក្នុងការបំប្លែងសិស្សពីអ្នកទទួលព័ត៌មានអសកម្មឱ្យក្លាយជាអ្នកស្រាវជ្រាវ និងជាអ្នកដោះស្រាយបញ្ហាយ៉ាងសកម្ម ។

